# "ការអនុលោមតាមតំរូវការទីផ្សារស្តីពី សុវត្ថិភាព និង គុណភាពចំណីអាហារ"

## សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់លើកទី ២

## "ការផ្សារភ្ជាប់កសិករក្រីក្រមកទីផ្សារ"

នៅថ្ងៃទី ១៩-២៣ ខែមករា ឆ្នាំ ២០០៩ នៅ សណ្ឋាគារមនោរាជ្យ ខេត្តសៀមរាប អង្គការ AsiaDHRRA បានសហការជាមួយមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ឬអង្គការ សេដាក (CEDAC) រៀបចំសិក្ខាសាលាបណ្តុះបណ្តលថ្នាក់តំបន់លើកទី ២ "**ការផ្សារភ្ជាប់កសិករក្រីក្រមកទីផ្សារ** "។ តំណាងកសិករ និងអង្គការមិនមែនរដ្ឋាភិបាលចំនួនជាង ៤០ នាក់ មកពីប្រទេសចំនួន ៧ ក្នុងតំបន់អាស៊ីរួមមានៈ ប្រទេសកម្ពុជា តៃវ៉ាន់ ថៃ ហ្វីលីពីន វៀតណាម ឥណ្ឌូនេស៊ី និងភូមា បានចូលរួមនៅក្នុងសិក្ខាសាលានេះ។ គោលបំណងរួមរបស់សិក្ខាសាលាបណ្តុះបណ្តាលនេះគឺ ផ្តល់នូវព័តិមានដល់បណ្តាប្រទេសមួយចំនួនដើម្បីយកទៅពង្រឹង សមត្ថភាពអោយស្របទៅតាមតម្រូវការ ផលិតកម្មជាក់លាក់ និង ទីផ្សារសំរាប់ផលិតផល ដែលមានសុវត្ថិភាព និងគុណភាព ដូច្នេះទីផ្សាររបស់គាត់នឹងមានភាពរឹងមាំ។ ការរៀបចំវគ្គបណ្តុះបណ្តលដើម្បីបញ្ជាក់ និង ផ្តល់នូវខ្លឹមសារច្បាស់លាស់ អំពីសុវត្ថិភាព និងគុណភាពផលិតផល។ រចនាសម្ព័ន្ធនេះផ្តល់នូវភាពបត់បែន ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តលអោយចំ ទៅនឹងតម្រូវការជាក់លាក់របស់ប្រទេសមួយៗ ដោយអនុញ្ញាតិអោយអ្នកចូលរួម បញ្ចេញនូវទស្សនៈអំពី តំរូវការសំរាប់បទដ្ឋាន សុវត្ថិភាព និងគុណភាពចំណីអាហារ។ ការស្វែងរក និង ការឈានចូលទៅកាន់ទីផ្សារ ដែលនឹងផ្តល់ជូនពួកគាត់នូវលទ្ធភាពល្អប្រសើរជាងមុន គឺអាចជាការលំបាក ហើយកសិករតូចតាច តែងតែប្រឈមមុខនឹងការលំបាកជាច្រើន។ការសិក្សាមួយចំនួនបានបង្ហាញនូវបញ្ហា ដែលកសិករក្រីក្រប្រឈម នៅពេលដែល ពួកគេចង់ផ្សារភ្ជាប់មកទីផ្សារថ្មី ឬចង់មានការប្រកួតប្រជែងកាន់តែខ្លាំងជាងមុននៅក្នុងទីផ្សារដែលមានស្រាប់។ ក្នុងឆ្នាំ ២០០៧ ធនាគារពិភពលោក បានធ្វើការកត់សំគាល់នូវបញ្ហាចំនួន ៥ ដូចខាងក្រោមៈ



១-កង្វះខាតនូវការឈានចូលទៅកាន់ទីផ្សារ

២-សមត្ថភាពបច្ចេកទេសខ្សោយ

៣-មិនទាន់បំពេញនូវបទដ្ឋានគុណភាព

៤-មិនមានលក្ខខ័ណ្ឌកិច្ចសន្យាត្រឹមត្រូវ

៥-ការបង្ហាញនូវការប្រចុប្រថានមួយចំនួនផ្សេងទៀត

គួរបញ្ជាក់ថា សិក្ខាសាលានេះ គឺជាសិក្ខាសិលាលើកទី ២ ហើយក្នុងចំណោមសិក្ខាសាលាចំនួន ៣ នៅក្នុងក៏រិតតំបន់។